# ចាប់ផ្តើមដោយប្រើសេវាថែទាំកុមារតូចសម្រាប់ឲ្យកុមារសិក្សាភាសាអង់គ្លេសជាភាសាបន្ថែម។

ការចាប់ផ្តើមវិជ្ជមានក្នុងការប្រើសេវាថែទាំកុមារតូចមាន សារៈសំខាន់។

ជាការសំខាន់ មាតាបីតា និង កុមារគប្បីទៅទស្សនាសេវា ថែទាំកុមារតូច នៅពេលមុនពេលចាប់ផ្តើមប្រើសេវានេះ។ គួរចាប់ផ្តើមដោយដាក់កុមាររយៈពេលខ្លីនៅទីកន្លែងដែល អាចធ្វើទៅបាន ហើយ បង្កើនរយៈពេលវែងជាងនេះជា បណ្តើៗ ដើម្បីជួយកុមារឲ្យសម្រួខ្លួន និង មានអារម្មណ៍កក់ក្តៅ នៅក្នុងកន្លែងថែទាំកុមារតូច។

មាតាបីតាអាចរំពឹងឲ្យអ្នកអប់រំបង្ហាញភាពកក់ក្តៅ និងការ ស្វាគមន៍ និង លើកទឹកចិត្តការប្រើភាសាផ្សេងៗ ក្រៅពី ភាសាអង់គ្លេស។ សេវាថែទាំកុមារតូចភាគច្រើនបំផុតមាន លទ្ធភាពផ្តល់សេវាបកប្រែតាមទូរស័ព្ទសម្រាប់មាតាបីតា ដែលអភិវឌ្ឍភាសាអង់គ្លេសជាភាសាបន្ថែមដើម្បីជួយពួក គេឲ្យយល់ព័ត៌មាន។ បន្ថែមពីនេះ ការគាំទ្រការនិយាយ ពីរភាសាអាចមានក្នុងរយៈពេលខ្លីដើម្បីជួយកុមារដែល និយាយភាសាក្រៅពីភាសាអង់គ្លេសឲ្យអាចសម្របខ្លួន បាននៅក្នុងសេវាថែទាំកុមារតូច។

អ្នកអប់រំសំដែងការស្វាគមន៍ចំពោះការចូលរួមរបស់មាតាបីតានៅក្នុងផ្នែកផ្សេងៗនៃកម្មវិធីថែទាំកុមារតូច។ ការធ្វើបែបនេះជួយកុមារឲ្យមានអារម្មណ៍ថាបានទទួលការស្វា គមន៍ ហើយមានការផ្សារភ្ជាប់ជាមួយនឹងផ្ទះ និង កន្លែង ផ្តល់សេវាថែទាំកុមារតូច។ ការផ្សារភ្ជាប់នេះជួយមាតា បីតាឲ្យយល់នូវសកម្មភាពនានាដែលកើតមានឡើង នៅក្នុងកន្លែងផ្តល់សេវាថែទាំកុមារ នៅពេលកូនរបស់ពួកគេ ស្នាក់នៅកន្លែងថែទាំដោយគ្មានវត្តមានរបស់ពួកគេ។

# មធ្យោបាយនានាដែលមាតាបីតាអាចជួយកូនរបស់ពួកគេឲ្យសម្របខ្លួននៅក្នុងកន្លែងផ្តល់សេវាថែទាំកុមារតូច។

- ចំណាយពេលវេលាជាមួយកូនពួកគេនៅកន្លែងផ្តល់សេ វាថែទាំកុមារតូច ដោយរៀបរាប់ពីសកម្មភាពប្រចាំថ្ងៃ របស់សេវាដល់កូនរបស់ពួកគេ លេង អានរឿង ច្រៀង ចម្រៀង និយាយជាមួយកុមារផ្សេងទៀត។
- និយាយជាមួយកូនពួកគេអំពីអ្វីដែលកូនជួបប្រទះ និង ចាប់អារម្មណ៍៖ ជួយផ្តល់ទំនុកចិត្ត និង លើកទឹកចិត្ត កូន។

អ្នកអប់រំនឹងចង់ស្វែងយល់ និងគោរពវប្បធម៌ និង ទំនៀម ទម្លាប់របស់គ្រួសារ និងមានការយល់ដឹងដោយក្តីគោរព ចំពោះបទពិសោធន៍ពីអតីតកាល។ ការចែករំលែកព័ត៌មានគ្រួសារជាមួយអ្នកអប់រំជួយពួកគេឲ្យយល់បាន កាន់តែច្បាស់អំពីកុមារ គ្រួសារ ភាសា និងមធ្យោបាយ រស់នៅ និង បទពិសោធន៍របស់កុមារ។ ឧទាហរណ៍ព័ត៌មានដែលមាតាបីតាផ្តល់ដល់កន្លែងផ្តល់សេវាថែទាំកុមារ តូចរួមមាន៖









- ព័ត៌មានអំពីសុខភាពកូន ដូចជាការចាក់ថ្នាំបង្ការ តម្រូវការព្យាបាលសុខភាព ជំងឺ ឬអាលែកហ្ស៊ី។
- របៀបមាតាបីតាប្តូរកន្ទបកូន។
- របៀបកូនប្រើប្រាស់បង្គន់អនាម័យ (បង្គន់អនាម័យនៅកន្លែងថែទាំកុមារតូចមិនមានទ្វារទេដើម្បីអនុញ្ញាតឲ្យអ្នកអប់រំអាចត្រួតមើលកូន និង ជួយវាប្រសិន បើចាំ បាច់)។
- ម្ហូបអាហារកូនញ៉ាំ ទម្លាប់ពេលញ៉ាំអាហារ/សកម្មភាព ប្រចាំថ្ងៃ។
- របៀបបញ្ចុកអាហារកូន ឬរបៀបកូនញ៉ាំអាហារខ្លួនឯង។
- តម្រូវការសម្រាក/ដំណេករបស់កូន៖ ឧទាហរណ៍ ចម្រៀងមាតាបីតាច្រៀង សៀវភៅកូនចូលចិត្តជាងគេ របស់លេង ឬភួយពិសេស ហើយនិងពេលកូនតែងតែ សម្រាក/គេងនៅពេលថ្ងៃ។
- របៀបមាតាបីតាលួងកូន។
- របៀបមាតាបីតាជួយកែសម្រួលទង្វើកូន ឧទាហរណ៍ ដូចជាវិធីអប់រំកូនដែលមាតាបីតាប្រើនៅផ្ទះ។
- របស់ដែលកូនចូលចិត្តលេង។
- ការប្រារព្ធពិធី និងប្រពៃណីរបស់គ្រួសារ និង វប្បធម៌។

## ការនាំយកភាសាកំណើត និង វប្បធម៌របស់កុមារ ចូលក្នុងកន្លែងថែទាំកុមារតូច៖

អ្នកអប់រំជួយបង្កើនចំណេះដឹង និង បំណិនផ្នែកអក្សរ និង លេខ ដោយឲ្យកុមារចូលរួមក្នុងការពិភាក្សា ការលើកទឹកចិត្តកុមារឲ្យអភិវឌ្ឍបំណិនគិតតាមរយៈការសម្តែងរឿង ការចែករំលែកសៀវភៅអាន និងការអានរឿង ការច្រៀង ចម្រៀង និង ការលេងជាមួយកុមារផ្សេងទៀត។ បទពិសោធន៍ទាំងនេះក៏នឹងជួយកុមារឲ្យរៀនភាសាអង់គ្លេស ផងដែរ។

អ្នកអប់រំលើកទឹកចិត្តមាតាបីតាឲ្យ៖

- អានសៀវភៅរូបភាព និងនិទានរឿងឲ្យកូនស្តាប់ជា ភាសាកំណើត និងកុមារផ្សេងទៀតនៅក្នុងកន្លែងថែទាំ កុមារតូច។
- ចំណាយពេលវេលានិយាយជាមួយកូន និង កុមារដទៃ ដែលនិយាយភាសាដូចគ្នា
- បង្រៀនអ្នកអប់រំឲ្យច្រៀងចម្រៀង សូត្រពាក្យចួន និង កំណាព្យជាភាសាពួកគេដែលអ្នកអប់រំអាចប្រើជាមួយ កុមារទាំងអស់បាន។
- យកបទភ្លេងដែលជាវប្បធម៌របស់ពួកគេ ដូចជាបទភ្លេង ចតរូច ឬឧបករណ៍ភ្លេង។
- យកសម្ភារៈដែលពិសេស ឬតែងតែប្រើប្រាស់ក្នុងវប្បធម៌ ពួកគេ ដូចជារូបភាព និងវត្ថុដែលបន្សល់ទុកពីសម័យ បុរាណ។

fka CHILDREN'S SERVICES INC
Incorporating Multicultural Resource Centre

Ground Floor, 9-11 Stewart Street
Richmond, 3121
tel: +61 3 9428 4471
fax: +61 3 9429 9252
email: fkacs@fka.org.au
web: www.fka.org.au
FKA Children's Services Inc. 215663278505573

Information for families: Handout 2 - Khmer

ព័ត៌មានសម្រាប់គ្រួសារៈ ក្រដាសកិច្ចការទី ២







